ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ:......១០០..........ប្រក.សក.ដជគ

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធបង្ហូរទឹកកខ្វក់ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធបង្ហូរទឹកកខ្វក់ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅកំណត់លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជី និងការផ្តល់លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោក ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុន ដែលផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោក ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.-**

ក្រុមហ៊ុនដែលផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល សម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវមានវិញ្ញាបនបត្រចុះបញ្ជី និងលិខិតអនុញ្ញាតធ្វើអាជីវកម្មចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ ៥.-**

ម្ចាស់ក្រុមហ៊ុន ឬអ្នកតំណាងស្របច្បាប់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជី លិខិតអនុញ្ញាតឱ្យក្រុមហ៊ុននិងសាខាក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស តាមប្រព័ន្ធស្វ័យប្រវត្តិកម្មសេវាដឹកជញ្ជូនផ្លូវគោក ដែលមានអាសយដ្ឋានគេហទំព័រ https://lts.mpwt.gov.kh របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដូចមាននៅក្នុង**ឧបសម្ព័ន្ធទី១** នៃប្រកាសនេះ។

**ក.** ការផ្តល់ និងការប្តូរវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោយបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវភ្ជាប់សំណុំឯកសារដូចខាងក្រោម៖

- អត្តសញ្ញាណរបស់ប្រធានក្រុមហ៊ុន៖
    - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លងដែលបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច)
    - លិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព ជាច្បាប់ថតចម្លង
    - លិខិតបញ្ជាក់ទីលំនៅដែលបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច (ករណីប្រធានក្រុមហ៊ុនជាជនបរទេស)
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន
- វិញ្ញាបនបត្រសេវាអនឡាញ ចេញដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ទីតាំងក្រុមហ៊ុនដែលមានការអនុញ្ញាតពីអាជ្ញាធរដែនដី
- កិច្ចសន្យាជួលទីតាំង (ករណីម្ចាស់ក្រុមហ៊ុនមិនមែនជាម្ចាស់កម្មសិទ្ធិ)
- បណ្ណប៉ាតង់។

**ខ.** ការផ្តល់ និងការបន្តលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវភ្ជាប់សំណុំឯកសារដូចខាងក្រោម៖

- អត្តសញ្ញាណរបស់ប្រធានក្រុមហ៊ុន៖
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
    (ច្បាប់ថតចម្លងដែលបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច)
  - លិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព ជាច្បាប់ថតចម្លង
  - លិខិតបញ្ជាក់ទីលំនៅដែលបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច (ករណីប្រធានក្រុមហ៊ុនជាជនបរទេស)
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- វិញ្ញាបនបត្រសេវាអនឡាញ ចេញដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
- ទីតាំងក្រុមហ៊ុនដែលមានការអនុញ្ញាតពីអាជ្ញាធរដែនដី
- កិច្ចសន្យាជួលទីតាំង (ករណីម្ចាស់ក្រុមហ៊ុនមិនមែនជាម្ចាស់កម្មសិទ្ធិ)
- តារាងស្ថិតិយានយន្តដែលបានចុះឈ្មោះក្នុងប្រព័ន្ធ
- បណ្ណប៉ាតង់។

**គ.** ការផ្តល់ ការបន្ត និងការប្តូរលិខិតអនុញ្ញាតឱ្យសាខាក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវភ្ជាប់សំណុំឯកសារដូចខាងក្រោម៖

- អត្តសញ្ញាណរបស់ប្រធានសាខាក្រុមហ៊ុន៖
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
    (ច្បាប់ថតចម្លងដែលបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច)
  - លិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព ជាច្បាប់ថតចម្លង
  - លិខិតបញ្ជាក់ទីលំនៅ ចេញដោយអាជ្ញាធរមានសមត្ថកិច្ច (ករណីប្រធានសាខាក្រុមហ៊ុនជាជនបរទេស)
- វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
- លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
- ទីតាំងសាខាក្រុមហ៊ុនដែលមានការអនុញ្ញាតពីអាជ្ញាធរដែនដី
- កិច្ចសន្យាជួលទីតាំងសាខាក្រុមហ៊ុន (ករណីម្ចាស់ក្រុមហ៊ុនមិនមែនជាម្ចាស់កម្មសិទ្ធិ)
- បណ្ណប៉ាតង់ (សាខាក្រុមហ៊ុន)
- តារាងស្ថិតិយានយន្តដែលបានចុះឈ្មោះនៅសាខាក្នុងប្រព័ន្ធ។

ទម្រង់ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន លិខិតអនុញ្ញាតឱ្យក្រុមហ៊ុន និងលិខិតអនុញ្ញាតឱ្យសាខាក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ដូចមាននៅក្នុង**ឧបសម្ព័ន្ធទី២** នៃប្រកាសនេះ។

ការប្តូរនាមករណ៍ក្រុមហ៊ុន ត្រូវមានលិខិតអនុញ្ញាតផ្លាស់ប្តូរថ្មីដែលចេញដោយក្រសួងពាណិជ្ជកម្ម។ ចំពោះការប្តូរអាសយដ្ឋានក្រុមហ៊ុន ឬសាខាក្រុមហ៊ុន ត្រូវមានលិខិតបញ្ជាក់អាសយដ្ឋាន ទីតាំងថ្មីពីអាជ្ញាធរដែនដី។

**ប្រការ ៦.-**

វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស មានសុពលភាពអចិន្ត្រៃយ៍។

លិខិតអនុញ្ញាតឱ្យក្រុមហ៊ុន និងសាខាក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស មានសុពលភាព ២(ពីរ)ឆ្នាំម្តង។

**ប្រការ ៧.-**

លិខិតអនុញ្ញាតឱ្យក្រុមហ៊ុន ឬសាខាក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស នឹងត្រូវបានដកហូត ឬព្យួរមិនឱ្យធ្វើអាជីវកម្មក្នុងរយៈពេល៣(បី)ខែ ទៅ៦(ប្រាំមួយ)ខែ ក្នុងករណីក្រុមហ៊ុនមិនអនុវត្តតាមប្រការ៩នៃប្រកាសនេះ និងមិនគោរពតាមការណែនាំរបស់ ក្រសួងសាធារណការ និងដឹកជញ្ជូន។

ក្នុងករណីក្រុមហ៊ុនបិទ ឬផ្អាកអាជីវកម្មរបស់ខ្លួន ក្រុមហ៊ុន ឬសាខាក្រុមហ៊ុនត្រូវធ្វើលិខិតជូនដំណឹងជាផ្លូវការមកអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

**ប្រការ ៨.-**

**ក.** វិញ្ញាបនបត្រចុះបញ្ជី និងលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស នឹងត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិក្នុងករណីដូចខាងក្រោម៖

- សាលក្រមរបស់តុលាការបានសម្រេចហាមឃាត់ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុន
- ក្រុមហ៊ុនត្រូវបានលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម
- ក្រុមហ៊ុនត្រូវបានដកហូតវិញ្ញាបនបត្រសេវាអនឡាញ។

**ខ.** លិខិតអនុញ្ញាតឱ្យសាខាក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស នឹងត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិក្នុងករណីដូចខាងក្រោម៖

- សាលក្រមរបស់តុលាការបានសម្រេចហាមឃាត់ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុន
- សាលក្រមរបស់តុលាការបានសម្រេចហាមឃាត់ការធ្វើអាជីវកម្មរបស់សាខាក្រុមហ៊ុន
- លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសអស់សុពលភាព
- ក្រុមហ៊ុនបានប្រកាសបិទសាខា។

**ប្រការ ៩.-**

ក្រុមហ៊ុន និងសាខាក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវបើកវគ្គបណ្តុះបណ្តាលអ្នកបើកបរដែលជាសមាជិករបស់ខ្លួនឱ្យបានយល់ដឹងអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក សុជីវធម៌ សីលធម៌ក្នុងការបើកបរ និងការបម្រើសេវាជូនអតិថិជន។

ក្រុមហ៊ុន និងសាខាក្រុមហ៊ុន ធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស តម្រូវឱ្យសមាជិកអ្នកបើកបរយានយន្តទាំងអស់ត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖

- បណ្ណបើកបរយានយន្ត ដែលម្ចាស់បណ្ណមានសញ្ជាតិខ្មែរ
- បណ្ណសម្គាល់យានយន្ត និងផ្លាកលេខ
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត (លើកលែងទោចក្រយានយន្ត)
- លិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស (លើកលែងតែទោចក្រយានយន្ត ត្រីចក្រយានយន្ត និងទោចក្រយានយន្តសណ្តោងរ៉ឺម៉ក)
- និមិត្តសញ្ញាសម្គាល់ក្រុមហ៊ុននៅលើយានយន្ត
- បណ្ណសម្គាល់ខ្លួនកំណត់ដោយក្រុមហ៊ុន។

ក្រុមហ៊ុន និងសាខាក្រុមហ៊ុនទាំងអស់ ត្រូវផ្តល់សុវត្ថិភាពដល់អតិថិជនដែលប្រើប្រាស់សេវាកម្មរបស់ខ្លួន មានដូចជា៖

- នៅក្នុងកម្មវិធីទូរស័ព្ទដៃ ដែលអាចបង្ហាញរូបភាពនៃអ្នកបើកបរ និងអាចអនុញ្ញាតឱ្យអតិថិជនបង្ហាញ ទីតាំងខ្លួនទៅកាន់ទូរស័ព្ទដៃរបស់សាច់ញាតិ ឬមិត្តភក្តិ ឬអាជ្ញាធរមានសមត្ថកិច្ចណាមួយបានក្នុងករណីបន្ទាន់ចាំបាច់
- ត្រូវចាត់វិធានការម៉ឺងម៉ាត់ដាច់ខាតចំពោះរាល់មតិរិះគន់ទៅលើអ្នកបើកបរទាំងឡាយណាដែលបើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង សារធាតុញៀន ការប្រព្រឹត្តអំពើហឹង្សា និងអំពើបៀតបៀនផ្លូវភេទជាដើម។

**ប្រការ ១០.-**

ក្រុមហ៊ុន និងសាខាក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវចូលរួមអនុវត្តផែនការតាមវិធានសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងបរិស្ថានជាតិ ក្នុងវិស័យដឹកជញ្ជូនក្នុងការកាត់បន្ថយការកកស្ទះ គ្រោះថ្នាក់ចរាចរណ៍ និងការបំភាយសារធាតុពុល និងឧស្ម័នផ្ទះកញ្ចក់។

**ប្រការ ១១.-**

ក្រុមហ៊ុន និងសាខាក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវផ្តល់របាយការណ៍ប្រចាំខែមកអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ដូចមាននៅក្នុង**ឧបសម្ព័ន្ធទី៣** នៃប្រកាសនេះ។

**ប្រការ ១២.-**

ការផ្តល់វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន ការផ្តល់និងបន្តលិខិតអនុញ្ញាតឱ្យក្រុមហ៊ុន ឬសាខាក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវបង់កម្រៃសេវាសាធារណៈតាមការកំណត់នៅក្នុងប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ ១៣.-**

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ត្រូវគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងណែនាំដល់ក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ឱ្យបានត្រឹមត្រូវស្របតាមបទដ្ឋានគតិយុត្ត នៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន។

**ប្រការ ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ប្រធានអង្គភាពក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួន តាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ.ចន្ទ..១២កើត....ខែបឋមាសាឍឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..២១.....ខែមិថុនា....ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៥

**"ដើម្បីអនុវត្ត"**

- រាជកិច្ច
- ឯកសារកាលប្បវត្តិ

យោងប្រកាសលេខ ១០០ ប្រក.ឥតពឥគ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០២១

ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវា
តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

# ឧបសម្ព័ន្ធទី១

## គំនូសបំព្រួញអំពីដំណើរការផ្តល់វិញ្ញាបនបត្រចុះបញ្ជី និងលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស



## ឧបសម្ព័ន្ធទី២

ទម្រង់ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជី លិខិតអនុញ្ញាតឱ្យក្រុមហ៊ុន និងលិខិតអនុញ្ញាតឱ្យសាខាក្រុមហ៊ុន
ធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវា តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

គោត្តនាមនិងនាម.......................................................ភេទ.................សញ្ជាតិ........................

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ □ លិខិតឆ្លងដែន □..........................................................................

នាមករណ៍ក្រុមហ៊ុន...............................................................................................................

ប្រភេទអាជីវកម្ម....................................................................................................................

អាសយដ្ឋានបច្ចុប្បន្ន -ផ្ទះលេខ...............ផ្លូវ...............ភូមិ...................ឃុំ/សង្កាត់.......................

ក្រុង/ស្រុក/ខណ្ឌ...........................រាជធានី/ខេត្ត.............................លេខទូរស័ព្ទ........................

អ៊ីម៉ែល...............................................................................................................................

អាសយដ្ឋានក្រុមហ៊ុន.............................................................................................................

ថ្ងៃ..........................ខែ..............ឆ្នាំ..............ព.ស.២៥.....
ធ្វើនៅ......................... ថ្ងៃទី.............ខែ...............ឆ្នាំ២០.....

**ហត្ថលេខា និងត្រាក្រុមហ៊ុន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវា តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

គោត្តនាម និងនាម..................................................ភេទ.................សញ្ជាតិ............................

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ □ លិខិតឆ្លងដែន..........................................................................

នាមករណ៍ក្រុមហ៊ុន...................................................................................................................

ប្រភេទអាជីវកម្ម........................................................................................................................

វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មលេខ...........................................................................

អាសយដ្ឋានបច្ចុប្បន្ន -ផ្ទះលេខ.............ផ្លូវ...............ភូមិ....................ឃុំ/សង្កាត់.........................

ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត.........................លេខទូរស័ព្ទ..............................

អ៊ីម៉ែល........................................................................................................................................

អាសយដ្ឋានក្រុមហ៊ុន.................................................................................................................

ថ្ងៃ..........................ខែ.............ឆ្នាំ.............ព.ស.២៥.....
ធ្វើនៅ........................ ថ្ងៃទី.............ខែ...............ឆ្នាំ២០.....

**ហត្ថលេខា និងត្រាក្រុមហ៊ុន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំលិខិតអនុញ្ញាតឱ្យសាខាក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវា តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

គោត្តនាម និងនាម.................................................ភេទ...............សញ្ជាតិ..........................

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ □ លិខិតឆ្លងដែន □ ..........................................................

នាមករណ៍ក្រុមហ៊ុន.................................................................................................

ប្រភេទអាជីវកម្ម........................................................................................................

វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មលេខ........................................................

លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មលេខ............................................................

អាសយដ្ឋានបច្ចុប្បន្ន -ផ្ទះលេខ.............ផ្លូវ.............ភូមិ.................. ឃុំ/សង្កាត់.........................

ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត..........................លេខទូរស័ព្ទ.............................

អ៊ីម៉ែល.....................................................................................................................

អាសយដ្ឋានក្រុមហ៊ុន....................................................................................................

ថ្ងៃ..........................ខែ............ឆ្នាំ..................ព.ស.២៥.....
ធ្វើនៅ........................ ថ្ងៃទី.............ខែ................ឆ្នាំ២០.....

**ហត្ថលេខា និងត្រាក្រុមហ៊ុន**

ទម្រង់ពាក្យស្នើសុំប្តូរនាមករណ៍ក្រុមហ៊ុនលើវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មផ្តល់សេវាតាម
ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំប្តូរនាមករណ៍ក្រុមហ៊ុនលើវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

គោត្តនាម និងនាម..................................................ភេទ...............សញ្ជាតិ...........................

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ☐ លិខិតឆ្លងដែន ☐ ...........................................................

**នាមករណ៍ក្រុមហ៊ុនថ្មី**.......................................................................................

ពីនាមករណ៍ក្រុមហ៊ុនចាស់.......................................................................................

ប្រភេទអាជីវកម្ម..................................................................................................

វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មលេខ.......................................................................

អាសយដ្ឋានបច្ចុប្បន្ន -ផ្ទះលេខ.............ផ្លូវ..............ភូមិ......................ឃុំ/សង្កាត់.........................

ក្រុង/ស្រុក/ខណ្ឌ........................រាជធានី/ខេត្ត..........................លេខទូរស័ព្ទ..............................

អ៊ីម៉ែល...............................................................................................................

អាសយដ្ឋានក្រុមហ៊ុន..............................................................................................

ថ្ងៃ......................ខែ..............ឆ្នាំ..............ព.ស.២៥.....
ធ្វើនៅ....................... ថ្ងៃទី............ខែ..............ឆ្នាំ២០.....

**ហត្ថលេខា និងត្រាក្រុមហ៊ុន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំប្តូរអាសយដ្ឋានក្រុមហ៊ុនលើវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មផ្តល់សេវា តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

គោត្តនាម និងនាម......................................................ភេទ...............សញ្ជាតិ.......................

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ □ លិខិតឆ្លងដែន □ ..................................................................

នាមករណ៍ក្រុមហ៊ុន..................................................................................................

ប្រភេទអាជីវកម្ម.......................................................................................................

វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មលេខ.......................................................................

អាសយដ្ឋានបច្ចុប្បន្ន -ផ្ទះលេខ.............ផ្លូវ...............ភូមិ....................ឃុំ/សង្កាត់.........................

ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត.........................លេខទូរស័ព្ទ..........................

អ៊ីម៉ែល....................................................................................................................

អាសយដ្ឋានចាស់របស់ក្រុមហ៊ុន.................................................................................

**អាសយដ្ឋានថ្មីរបស់ក្រុមហ៊ុន**..................................................................................

ថ្ងៃ.........................ខែ.............ឆ្នាំ..............ព.ស.២៥......
ធ្វើនៅ........................ ថ្ងៃទី.............ខែ...............ឆ្នាំ២០......

**ហត្ថលេខា និងត្រាក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យស្នើសុំប្តូរអាសយដ្ឋានសាខាក្រុមហ៊ុនលើវិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្ម ផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូន ផ្លូវគោកក្នុងប្រទេស

គោត្តនាម និងនាម..................................................ភេទ...............សញ្ជាតិ.........................

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ □ លិខិតឆ្លងដែន □ .................................................................

នាមករណ៍ក្រុមហ៊ុន.........................................................................................................

ប្រភេទអាជីវកម្ម..............................................................................................................

វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មលេខ...................................................................

លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មលេខ.....................................................................

អាសយដ្ឋានបច្ចុប្បន្ន -ផ្ទះលេខ.............ផ្លូវ.............ភូមិ...................ឃុំ/សង្កាត់.........................

ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត..........................លេខទូរស័ព្ទ..........................

អ៊ីម៉ែល..........................................................................................................................

អាសយដ្ឋានចាស់របស់សាខាក្រុមហ៊ុន.............................................................................

**អាសយដ្ឋានថ្មីរបស់សាខាក្រុមហ៊ុន**...........................................................................

ថ្ងៃ.........................ខែ.............ឆ្នាំ.................ព.ស.២៥......

ធ្វើនៅ...................... ថ្ងៃទី............ខែ..............ឆ្នាំ២០.....

ហត្ថលេខា និងត្រាក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងសាធារណការ និងដឹកជញ្ជូន
MINISTRY OF PUBLIC WORKS AND TRANSPORT
**លេខ(No)៖............................................**

# វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវា តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
LICENSE OF DOMESTIC DIGITAL HAILING SERVICE FOR ROAD TRANSPORT OPERATION

នាមករណ៍ក្រុមហ៊ុន..........................................................................................ប្រភេទអាជីវកម្ម..............................
ចុះបញ្ជីលេខ.......................................................................ចុះថ្ងៃទី...............ខែ.................ឆ្នាំ..........................
អាសយដ្ឋាន ..........................................................................................................................................
Company name..........................................................................................................................................
Registration Number...................................................Date...................................................................
Address.......................................................................................................................................

វិញ្ញាបនបត្រនេះ មិនចាំបាច់មានហត្ថលេខា
The Signature is not required in this License

**សម្គាល់៖** វិញ្ញាបនបត្រនេះមានទំហំ A4

ក្រសួងសាធារណការ និងដឹកជញ្ជូន
MINISTRY OF PUBLIC WORKS AND TRANSPORT
លេខ(No)៖............................................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

# វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវា តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

## LICENSE OF DOMESTIC DIGITAL HAILING SERVICE FOR ROAD TRANSPORT OPERATION

នាមករណ៍ក្រុមហ៊ុន..........................................................ប្រភេទអាជីវកម្ម..............................
ចុះបញ្ជីលេខ..........................................................ចុះថ្ងៃទី...............ខែ.................ឆ្នាំ..........................
អាសយដ្ឋាន ..........................................................................................................

Company name..........................................................................................................
Registration Number..........................................................Date..........................................
Address..........................................................................................................

វិញ្ញាបនបត្រនេះ មិនចាំបាច់មានហត្ថលេខា
The Signature is not required in this License

**សម្គាល់៖** វិញ្ញាបនបត្រនេះមានទំហំ A4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងសាធារណការ និងដឹកជញ្ជូន
MINISTRY OF PUBLIC WORKS AND TRANSPORT
អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
GENERAL DEPARTMENT OF LAND TRANSPORT
លេខ(No)៖.............................................

# លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវា តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

# CERTIFICATE OF DOMESTIC DIGITAL HAILING SERVICE FOR ROAD TRANSPORT OPERATION

នាមករណ៍ក្រុមហ៊ុន.................................................................................................ប្រភេទអាជីវកម្ម.............................
វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនលេខ...................................................................ចុះថ្ងៃទី..................ខែ...................ឆ្នាំ.........................
អាសយដ្ឋាន .........................................................................................................................................................................
កាលបរិច្ឆេទចេញ...............................................................................កាលបរិច្ឆេទផុតសុពលភាព...........................................
Company name........................................................................................................................................................
Registration Number..............................................................Date.......................................................................
Address....................................................................................................................................................................
Date of Issue...........................................................................Date of Expiry...........................................................

លិខិតអនុញ្ញាតនេះ មិនចាំបាច់មានហត្ថលេខា
The Signature is not required in this certificate

**សម្គាល់៖** លិខិតអនុញ្ញាតនេះមានទំហំ A4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងសាធារណការ និងដឹកជញ្ជូន
MINISTRY OF PUBLIC WORKS AND TRANSPORT
មន្ទីរសាធារណការ និងដឹកជញ្ជូន.........................
DEPARTMENT OF PUBLIC WORKS AND TRANSPORT............
លេខ(No)៖...........................................

# លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនបើកសាខាធ្វើអាជីវកម្មផ្តល់សេវា តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
# CERTIFICATE OF BRANCH DOMESTIC DIGITAL HAILING SERVICE FOR ROAD TRANSPORT OPERATION

នាមករណ៍ក្រុមហ៊ុន.............................................................................................ប្រភេទអាជីវកម្ម.............................
វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនលេខ.........................................................ចុះថ្ងៃទី..............ខែ.................ឆ្នាំ.........................
លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនលេខ............................................................ចុះថ្ងៃទី..............ខែ.................ឆ្នាំ.........................
អាសយដ្ឋាន ........................................................................................................................................................
កាលបរិច្ឆេទចេញ...................................................................កាលបរិច្ឆេទផុតសុពលភាព.............................................
Company name...........................................................................................................................................
Registration Number...............................................Date...................................................................................
Certificate Number..................................................Date...................................................................................
Address..........................................................................................................................................................
Date of Issue...........................................Date of Expiry..........................................................

លិខិតអនុញ្ញាតនេះ មិនចាំបាច់មានហត្ថលេខា
The Signature is not required in this certificate

**សម្គាល់៖** លិខិតអនុញ្ញាតនេះមានទំហំ A4

## ឧបសម្ព័ន្ធទី៣

ទម្រង់របាយការណ៍ប្រចាំខែនៃការធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

### ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមហ៊ុន៖** ........................................................................ ប្រភេទអាជីវកម្ម..............................................

**លិខិតអនុញ្ញាតលេខ៖**......................................... កាលបរិច្ឆេទចេញ........................................ កាលបរិច្ឆេទផុតសុពលភាព..................................

### របាយការណ៍ប្រចាំខែនៃការធ្វើអាជីវកម្មផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់មធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

| ល.រ | អត្តសញ្ញាណ | | | លេខសម្គាល់ និងសុពលភាព | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ប្រភេទយានយន្ត | ផ្លាកលេខយានយន្ត | លេខកូដសមាជិកចុះក្នុងប្រព័ន្ធ | បណ្ណបើកបរ | វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេស | លិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្ម | |
| 1 | | | | | | | |
| 2 | | | | | | | |
| 3 | | | | | | | |
| 4 | | | | | | | |
| 5 | | | | | | | |
| 6 | | | | | | | |
| 7 | | | | | | | |
| 8 | | | | | | | |
| 9 | | | | | | | |